# ហោរបរិត្ត (ធមិឧធេតយញ្ញ អបេតយញ្ញ)

## (សេចក្តីអធិប្បាយតាមបិដក និង អដ្ឋកថា)

## បិដកខ្មែរភាគ ៥៨



ដកស្រង់រៀបរៀងដោយភិក្ខុ នួន សារ៉េត ព.ស២៥៦៦, គ.ស២០២៣

# សេចក្តីផ្តើម

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ នួន សារ៉េត បានរៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និងបដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនា របស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជានិស្សិត ក្នុងសៀវភៅនេះផងដែរ ។

ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹងឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ លូតលាស់ ជឿនលឿន ប្រកបដោយសុខចម្រើន ក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះនឹងបានជាយោជន៍ដល់ជនច្រើន ។

សេចក្តីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សា បដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិត សម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្តីសុខ សេចក្តីចម្រើន និង រួចចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទាន ដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្តីសុខ សេចក្តីចម្រើន និងរួចចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

*វត្តស្រះមុជ្ជលិន្ទ ថ្ងៃទី០៦ ខែមេសាឆ្នាំ២០២៣*

ភិក្ខុសារត្ថធម្មោ នួន សារ៉េត

## មោរជាតកំ (ឧទេតយញ្ច អបេតយញ្ច)

[១៦៧] ឧទេតយំ ចក្ខុមា ឯករាជា, ហរិស្សវណ្ណោ បថវិប្បភាសោ;
តំ តំ នមស្សាមិ ហរិស្សវណ្ណំ បថវិប្បភាសំ, តយាជ្ជ គុត្តា វិហរេមុ ទិវសំ។
យេ ព្រាហ្មណា វេទគូ សព្វធម្មេ, តេ មេ នមោ តេ ច មំ បាលយន្តុ;
នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា, នមោ វិមុត្តានំ នមោ វិមុត្តិយា;
ឥមំ សោ បរិត្តំ កត្វា, មោរោ ចរតិ ឯសនា។

[១៦៨] អបេតយំ ចក្ខុមា ឯករាជា, ហរិស្សវណ្ណោ បថវិប្បភាសោ;
តំ តំ នម្មស្សាមិ ហរិស្សវណ្ណំ បថវិប្បភាសំ, តយាជ្ជ គុត្តា វិហរេមុ រត្តិំ។
យេ ព្រាហ្មណា វេទគូ សព្វធម្មេ, តេ មេ នមោ តេ ច មំ បាលយន្តុ;
នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា, នមោ វិមុត្តានំ នមោ វិមុត្តិយា;
ឥមំ សោ បរិត្តំ កត្វា, មោរោ វាសមកប្បយីតិ។

## មោរជាតក ទី៩

[១៦៧] (ក្ងោកពោធិសត្វ ពោលថា) សុរិយទេវបុត្រណា ជាឯករាជ មានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី កំពុងរះឡើង ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្រនោះ អ្នកមានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សា អស់វេលាថ្ងៃក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណា សំរេចនូវវេទ ក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងឡាយនោះ ទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងឡាយនោះ រក្សានូវខ្ញុំ ការនមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការ

នមស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វនោះ ធ្វើបរិត្តនេះរួចហើយ ទើបត្រាច់ទៅស្វែងរកអាហារ។

[១៦៨] (សុរិយទេវបុត្រណា) ជាឯករាជ មានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី កំពុងអស្តង្គតទៅ ខ្ញុំសូមនមស្ការ នូវសុរិយទេវបុត្រនោះ អ្នកមានសម្បុរដូចមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សា អស់រាត្រីក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណា សំរេចនូវវេទ ក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងនោះ ទទួលនូវការនមស្ការបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងនោះ រក្សានូវខ្ញុំ ការនមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វ ធ្វើបរិត្តនេះរួចហើយ ទើបបានសម្រេចការនៅ។

ចប់ មោរជាតក ទី៩ ។

## ៩. មោរជាតកវណ្ណនា

[១៦៧]ឧទេតយំ ចក្ខុមា ឯករាជាតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ ឯកំ ឧក្កណ្ឋិតភិក្ខុំ អារព្ភ កថេសិ។ សោ ហិ ភិក្ខុ ភិក្ខូហិ សត្ថុ សន្តិកំ នីតោ "សច្ចំ កិរ, ត្វំ ភិក្ខុ, ឧក្កណ្ឋិតោ"តិ វុត្តេ "សច្ចំ, ភន្តេ"តិ វត្វា "កឹ ទិស្វា"តិ វុត្តេ "ឯកំ អលង្កតបដិយត្តសរីរំ មាតុគាមំ ឱលោកេត្វា"តិ អាហ។ អថ នំ សត្ថា "ភិក្ខុ មាតុគាមោ នាម កស្មា តុម្ហាទិសានំ ចិត្តំ នាលុឡេស្សតិ, បោរា-ណកបណ្ឌិតានម្បិ ហិ មាតុគាមស្ស សទ្ទំ សុត្វា សត្ត វស្សសតានិ អសមុទាចិណ្ណ

កិលេសា ឱកាសំ លភិត្វា ខណេនេវ សមុទាចរឹសុ។ វិសុទ្ធាបិ សត្តា សំកិលិស្សន្តិ, ឧត្តមយសសមង្គិ-នោបិ អាយសក្យំ បាបុណន្តិ, បគេវ អបរិសុទ្ធា”តិ វត្វា អតីតំ អាហរិ។

អតីតេ ពារាណសិយំ ព្រហ្មទត្តេ រជ្ជំ ការេន្តេ ពោធិសត្តោ មោរយោនិយំ បដិសន្ធឹ គហេត្វា អណ្ឌកាលេបិ កណិការមកុឡវណ្ណអណ្ឌកោសោ ហុត្វា អណ្ឌំ ភិន្ទិត្វា និក្ខន្តោ សុវណ្ណវណ្ណោ អហោសិ ទស្សនីយោ បាសាទិកោ បក្ខានំ អន្តរេ សុរត្តរាជិវិរាជិតោ, សោ អត្តនោ ជីវិតំ រក្ខន្តោ តិស្សោ បព្វតរាជិយោ អតិក្កម្ម ចតុត្ថាយ បព្ពតរាជិយា ឯកស្មឹ ទណ្ឌកហិរញ្ញបព្ពតតលេ វាសំ កប្បេសិ. សោ បភាតាយ រត្តិយា បព្ពតមត្ថកេ និសិន្នោ សូរិយំ ឧគ្គច្ឆន្តំ ឱលោកេត្វា អត្តនោ គោចរភូមិយំ រក្ខាវរណត្ថាយ ព្រហ្មមន្តំ ពន្ធន្តោ “ឧទេតយ”ន្តិ អាទិមាហ។

“ឧទេតយំ ចក្ខុមា ឯករាជា,
ហរិស្សវណ្ណោ បថវិប្បភាសោ;
តំ តំ នមស្សាមិ ហរិស្សវណ្ណំ បថវិប្បភាសំ,
តយាជ្ជ គុត្តា វិហរេមុ ទិវស”ន្តិ។

តត្ថ ឧទេតីតិ បាចីនលោកធាតុតោ ឧគ្គច្ឆតិ។ ចក្ខុមាតិ សកលចក្កវាឡវាសីនំ អន្ធការំ វិធមិត្វា ចក្ខុបដិលាភករណេន យំ តេន តេសំ ទិន្នំ ចក្ខុ, តេន ចក្ខុនា ចក្ខុមា។ ឯករាជាតិ សកលចក្កវាឡេ អាលោកករានំ អន្តរេ សេដ្ឋវិសិដ្ឋដ្ឋេន ឯករាជា។ ហរិស្សវណ្ណោតិ ហរិសមានវណ្ណោ, សុវណ្ណវណ្ណោតិ អត្ថោ។ បថវិប្បភាសោតិ បថវិយា បភាសោ។ តំ តំ នមស្សាមីតិ តស្មា តំ ឯវរូបំ ភវន្តំ នមស្សាមិ វន្ទាមិ។ តយាជ្ជ គុត្តា វិហរេមុ -ទិវសន្តិ តយា អជ្ជ រក្ខិតា គោបិតា ហុត្វា ឥមំ ទិវសំ ចតុឥរិយាបថវិហារេន សុខំ វិហរេយ្យាម។

ឯវំ ពោធិសត្តោ ឥមាយ គាថាយ សូរិយំ នមស្សិត្វា ទុតិយគាថាយ អតីតេ បរិនិព្វុ-តេ ពុទ្ធេ ចេវ ពុទ្ធគុណេ ច នមស្សតិ។

“យេ ព្រាហ្មណា វេទគូ សព្វធម្មេ,    តេ មេ នមោ តេ ច មំ បាលយន្តុ;
នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា,    នមោ វិមុត្តានំ នមោ វិមុត្តិយា;
ឥមំ សោ បរិត្តំ កត្វា,    មោរោ ចរតិ ឯសនា”តិ។

តត្ថ យេ ព្រាហ្មណាតិ យេ ពាហិតបាបា វិសុទ្ធិព្រាហ្មណា។ វេទគូតិ វេទានំ បារំ គតាតិបិ វេទគូ, វេទេហិ បារំ គតាតិបិ វេទគូ។ ឥធ បន សព្វេ សង្ខតាសង្ខតធម្មេ វិទិតេ បាកដេ កត្វា គតាតិ វេទគូ។ តេនេវាហ “សព្វធម្មេ”តិ។ សព្វេ ខន្ធាយតនធាតុធម្មេ សលក្ខណសាមញ្ញលក្ខណវសេន អត្តនោ ញាណស្ស វិទិតេ បាកដេ កត្វា គតា, តិណ្ណំ មារានំ មត្ថកំ មទ្ទិត្វា ទសសហស្សិលោកធាតុំ ឧន្នាទេត្វា ពោធិតលេ សម្មាសម្ពោធឹ បត្វា សំសារំ វា    អតិក្កន្តាតិ អត្ថោ។ តេ មេ នមោតិ តេ មម ឥមំ នមក្ការំ បដិច្ឆន្តុ។ តេ ច មំ បាលយន្តូតិ ឯវំ មយា នមស្សិតា ច តេ ភគវន្តោ មំ បាលេន្តុ រក្ខន្តុ គោបេន្តុ។ នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា, នមោ វិមុត្តានំ នមោ វិមុត្តិយាតិ អយំ មម នមក្ការោ អតីតានំ បរិនិព្វុតានំ ពុទ្ធានំ អត្ថុ, តេសញ្ញេវ ចតូសុ ច មគ្គេសុ ចតូសុ ផលេសុ ញាណសង្ខាតាយ ពោធិយា អត្ថុ, តថា តេសញ្ញេវ អរហត្តផលវិមុត្តិយា វិមុត្តានំ អត្ថុ, យា ច នេសំ តទង្គវិមុត្តិ វិក្ខម្ភ-នវិមុត្តិ សមុច្ឆេទវិមុត្តិ បដិប្បស្សទ្ធិវិមុត្តិ និស្សរណវិមុត្តីតិ បញ្ចវិធា វិមុត្តិ, តស្សា នេសំ វិមុត្តិយាបិ អយំ មយ្ហំ នមក្ការោ អត្ថូតិ។ “ឥមំ សោ បរិត្តំ កត្វា, មោរោ ចរតិ ឯសនា”តិ ឥទំ បន បទទ្វយំ សត្ថា អភិសម្ពុទ្ធោ ហុត្វា អាហ។ តស្សត្ថោ ភិក្ខវេ, សោ មោរោ ឥមំ បរិត្តំ ឥមំ រក្ខំ កត្វា អត្តនោ គោចរភូមិយំ បុប្ផផលាទីនំ អត្ថាយ នានប្បការាយ ឯសនាយ ចរតិ។

ឯវំ ទិវសំ ចរិត្វា សាយំ បព្ពតមត្ថកេ និសីទិត្វា អត្ថង្គតំ សូរិយំ ឱលោកេន្តោ ពុទ្ធគុ-
ណេ អាវជ្ជេត្វា និវាសដ្ឋានេ រក្ខាវរណត្ថាយ បុន ព្រហ្មមន្តំ ពន្ធន្តោ "អបេតយ"ន្តិ អាទិមា-
ហ។

[១៦៨] "អបេតយំ ចក្ខុមា ឯករាជា, ហរិស្សវណ្ណោ បថវិប្បភាសោ;
តំ តំ នមស្សាមិ ហរិស្សវណ្ណំ បថវិប្បភាសំ, តយាជ្ជ គុត្តា វិហរេមុ រត្តឹ។
"យេ ព្រាហ្មណា វេទគូ សព្ពធម្មេ, តេ មេ នមោ តេ ច មំ បាលយន្តុ;
នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា, នមោ វិមុត្តានំ នមោ វិមុត្តិយា;
ឥមំ សោ បរិត្តំ កត្វា, មោរោ វាសមកប្បយី"តិ។

តត្ថ អបេតីតិ អបយាតិ អត្ថំ គច្ឆតិ។ ឥមំ សោ បរិត្តំ កត្វា, មោរោ វាសមកប្បយីតិ
ឥទម្បិ អភិសម្ពុទ្ធោ ហុត្វា អាហ។ តស្សត្ថោ ភិក្ខវេ, សោ មោរោ ឥមំ បរិត្តំ ឥមំ រក្ខំ កត្វា
អត្តនោ និវាសដ្ឋានេ វាសំ កប្បយិត្ថ, តស្ស រត្តឹ វា ទិវា វា ឥមស្ស បរិត្តស្សានុភាវេន នេវ
ភយំ, ន លោមហំសោ អហោសិ។

អថេកោ ពារាណសិយា អវិទូរេ នេសាទគាមវាសី នេសាទោ ហិមវន្តបទេសេ វិចរ-
ន្តោ តស្មឹ ទណ្ឌកហិរញ្ញបព្ពតមត្ថកេ និសិន្នំ ពោធិសត្តំ ទិស្វា អាគន្ត្វា បុត្តស្ស អារោចេ-
សិ។ អថេកទិវសំ ខេមា នាម ពារាណសិរញ្ញោ ទេវី សុបិនេន សុវណ្ណវណ្ណំ មោរំ ធម្មំ ទេ-
សេន្តំ ទិស្វា បពុទ្ធកាលេ រញ្ញោ អារោចេសិ "អហំ, ទេវ, សុវណ្ណវណ្ណស្ស មោរស្ស ធម្មំ
សោតុកាមា"តិ។ រាជា អមច្ចេ បុច្ឆិ។ អមច្ចា "ព្រាហ្មណា ជានិស្សន្តី"តិ អាហំសុ។ ព្រាហ្ម-
ណា តំ សុត្វា "សុវណ្ណវណ្ណា មោរា នាម ហោន្តី"តិ វត្វា "កត្ថ ហោន្តី"តិ វុត្តេ "នេសាទា ជា-
និស្សន្តី"តិ អាហំសុ។ រាជា នេសាទេ សន្និបាតេត្វា បុច្ឆិ។ អថ សោ នេសាទបុត្តោ "អាម,
មហារាជ, ទណ្ឌកហិរញ្ញបព្ពតោ នាម អត្ថិ, តត្ថ សុវណ្ណវណ្ណោ មោរោ វសតី"តិ អាហ។

“តេន ហិ តំ មោរំ អមារេត្វា ពន្ធិត្វា អានេហី”តិ។ នេសាទោ គន្ត្វា តស្ស គោចរភូមិយំ បាសេ ឱឌ្ឌេសិ។ មោរេន អក្កន្តដ្ឋានេបិ បាសោ ន សញ្ចរតិ។ នេសាទោ គណ្ហិតុំ អសក្កោ-ន្តោ សត្ត វស្សានិ វិចរិត្វា តត្ថេវ កាលមកាសិ។ ខេមាបិ ទេវី បត្ថិតំ អលភមានា កាលមកា-សិ។

រាជា “មោរំ មេ និស្សាយ ទេវី កាលកតា”តិ កុជ្ឈិត្វា “ហិមវន្តបទេសេ ទណ្ឌកហិរញ្ញ-បព្វតោ នាម អត្ថិ, តត្ថ សុវណ្ណវណ្ណោ មោរោ វសតិ, យេ តស្ស មំសំ ខាទន្តិ, តេ អជរា - អមរា ហោន្តី”តិ អក្ខរំ សុវណ្ណបដ្ដេ លិខាបេត្វា សុវណ្ណបដ្ដំ មញ្ជូសាយ និក្ខិបាបេសិ។ តស្មឹ កាលកតេ អញ្ញោ រាជា រជ្ជំ បត្វា សុវណ្ណបដ្ដំ វាចេត្វា “អជរោ អមរោ ភវិស្សាមី”តិ អញ្ញំ នេសាទំ បេសេសិ។ សោបិ គន្ត្វា ពោធិសត្តំ គហេតុំ អសក្កោន្តោ តត្ថេវ កាលមកាសិ។ ឯតេនេវ និយាមេន ឆ រាជបរិវដ្ដា គតា។ អថ សត្តមោ រាជា រជ្ជំ បត្វា ឯកំ នេសាទំ បហិ-ណិ។ សោ គន្ត្វា ពោធិសត្តេន អក្កន្តដ្ឋានេបិ បាសស្ស អសញ្ចរ-ណភាវំ, អត្តនោ បរិត្តំ កត្វា គោចរភូមិគមនភាវញ្ចស្ស ញត្វា បច្ចន្តំ ឱតរិត្វា ឯកំ មោរឹ គហេត្វា យថា ហត្ថតាឡ-សទ្ទេន នច្ចតិ, អច្ឆរាសទ្ទេន ច វស្សតិ, ឯវំ សិក្ខាបេត្វា តំ អាទាយ គន្ត្វា មោរេន បរិត្តេ អកតេ បាតោយេវ បាសយដ្ឋិយោ រោបេត្វា បាសេ ឱឌ្ឌេត្វា មោរឹ វស្សាបេសិ។ មោរោ វិសភាគំ មាតុគាមសទ្ទំ សុត្វា កិលេសាតុរោ ហុត្វា បរិត្តំ កាតុំ អសក្កុណិត្វា គន្ត្វា បាសេ ពជ្ឈិ។ អថ នំ នេសាទោ គហេត្វា គន្ត្វា ពារាណសិរញ្ញោ អទាសិ។

រាជា តស្ស រូបសម្បត្តឹ ទិស្វា តុដ្ឋមានសោ អាសនំ ទាបេសិ។ ពោធិសត្តោ បញ្ញត្តាសនេ និសីទិត្វា “មហារាជ, កស្មា មំ គណ្ហាបេសី”តិ បុច្ឆិ។ “យេ កិរ តវ មំសំ ខាទន្តិ, តេ អជរា អមរា ហោន្តិ, ស្វាហំ តវ មំសំ ខាទិត្វា អជរោ អមរោ ហោតុកាមោ តំ គណ្ហាបេសិ”ន្តិ។ “មហារាជ, មម តាវ មំសំ ខាទន្តា អជរា អមរា ហោន្តុ, អហំ បន មរិស្សាមី”តិ? “អាម, មរិស្សសី”តិ។ “មយិ មរន្តេ បន មម មំសមេវ ខាទិត្វា កិន្តិ កត្វា ន មរិស្សន្តី”តិ? “ត្វំ

សុវណ្ណវណ្ណា, តស្មា កិរ តវ មំសំ ខាទកា អជរា អមរា ភវិស្សន្តី”តិ។ “មហារាជ, អហំ បន ន អការណា សុវណ្ណវណ្ណោ ជាតោ, បុព្វេ បនាហំ ឥមស្មឹយេវ នគរេ ចក្កវត្តិ រាជា ហុត្វា សយម្បិ បញ្ច សីលានិ រក្ខឹ, សកលចក្កវាឡវាសិនោបិ រក្ខាបេសឹ, ស្វាហំ កាលំ ករិត្វា តាវតឹសភវនេ និព្វត្តោ, តត្ថ យាវតាយុកំ ឋត្វា តតោ ចុតោ អញ្ញស្ស អកុសលស្ស និស្សន្ទេន មោរយោនិយំ និព្វត្តិត្វាបិ បោរាណសីលានុភាវេន សុវណ្ណវណ្ណោ ជាតោ”តិ។ “‘ត្វំ ចក្កវត្តិ រាជា ហុត្វា សីលំ រក្ខិត្វា សីលផលេន សុវណ្ណវណ្ណោ ជាតោ’តិ កថមិទំ អម្ហេហិ សទ្ធាតព្វំ។ អត្ថិ នោ កោចិ សក្ខី”តិ? “អត្ថិ, មហារាជា”តិ។ “កោ នាមា”តិ? “មហារាជ, អហំ ចក្កវត្តិកាលេ រតនមយេ រថេ និសីទិត្វា អាកាសេ វិចរឹ, សោ មេ រថោ មង្គលបោក្ខរណិយា អន្តោភូ - មិយំ និទហាបិតោ, តំ មង្គលបោក្ខរណិតោ ឧក្ខិបាបេហិ, សោ មេ សក្ខិ ភវិស្សតី”តិ។

រាជា “សាធូ”តិ បដិស្សុណិត្វា បោក្ខរណិតោ ឧទកំ ហរាបេត្វា រថំ នីហរាបេត្វា ពោធិសត្តស្ស សទ្ទហិ។ ពោធិសត្តោ “មហារាជ, ឋបេត្វា អមតមហានិព្វានំ អវសេសា សព្វេ សង្ខតធម្មា ហុត្វា អភាវិនោ អនិច្ចា ខយវយធម្មាយេវា’តិ រញ្ញោ ធម្មំ ទេសេត្វា រាជានំ បញ្ចសុ សីលេសុ បតិដ្ឋាបេ-សិ។ រាជា បសន្នោ ពោធិសត្តំ រជ្ជេន បូជេត្វា មហន្តំ សក្ការំ អកាសិ។ សោ រជ្ជំ តស្សេវ បដិនិយ្យាទេត្វា កតិបាហំ វសិត្វា “អប្បមត្តោ ហោហិ, មហា-រាជា”តិ ឱវទិត្វា អាកាសេ ឧប្បតិត្វា ទណ្ឌកហិរញ្ញបព្ពតមេវ អគមាសិ។ រាជាបិ ពោធិសត្តស្ស ឱវាទេ ឋត្វា ទានាទីនិ បុញ្ញានិ កត្វា យថាកម្មំ គតោ។

សត្ថា ឥមំ ធម្មទេសនំ អាហរិត្វា សច្ចានិ បកាសេត្វា ជាតកំ សមោធានេសិ, សច្ចបរិយោសានេ ឧក្កណ្ឋិតភិក្ខុ អរហត្តេ បតិដ្ឋហិ។ “តទា រាជា អានន្ទោ អហោសិ, សុវណ្ណមោរោ បន អហមេវ អហោសិ”ន្តិ។

មោរជាតកវណ្ណនា នវមា។

# អដ្ឋកថា មោរជាតកទី ៩

(ពោលអំពីសត្វក្ងោកជម្រើនព្រះបរិត្ត)

[១៦៧] ឧទេតយញ្ចក្ខុមា ឯករាជា
ហរិស្សវណ្ណោ បឋវិប្បភាសោ
តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ
តយជ្ជ គុត្តា វិហរេមុ ទិវសំ
យេ ព្រាហ្មណា វេទគុ[១] សព្វធម្មេ
តេ មេ នមោ តេ ច មំ បាលយន្តុ
នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា
នមោ វិមុត្តានំ នមោ វិមុត្តិយា
ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា ។

(ក្ងោកពោធិសត្វ ពោលថា) សុរិយទេវបុត្រណា ជាឯករាជ មានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី កំពុង

---

១. ម. វេទគូ ។

រះឡើង ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្រនោះ អ្នកមានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សា អស់វេលាថ្ងៃក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណាសម្រេចនូវវេទក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងឡាយនោះ ទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងឡាយនោះរក្សានូវខ្ញុំ ការនមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វនោះ ធ្វើបរិត្តនេះរួចហើយ ទើបត្រាច់ទៅស្វែងរកអាហារ ។

[១៦៨] អបេតយញ្ចក្ខុមា ឯករាជា
ហរិស្សវណ្ណោ បឋវិប្បភាសោ
តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ
តយជ្ជ គុត្តា វិហរេមុ រត្តឹ
យេ ព្រាហ្មណា វេទគុ សព្វធម្មេ

តេ មេ នមោ តេ ច មំ បាលយន្តុ

នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា

នមោ វិមុត្តានំ នមោ វិមុត្តិយា

ឥមំ សោ បរិត្តំ កត្វា មោរោ វាសមកប្បយីតិ ។

(សុរិយទេវបុត្តណា) ជាឯករាជ មានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី កំពុងអស្តង្គតទៅ ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្តនោះ អ្នកមានសម្បុរដូចមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សាអស់រាត្រីក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណា សម្រេចនូវវេទក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងនោះ ទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងនោះរក្សានូវខ្ញុំ ការនមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វធ្វើបរិត្តនេះរួចហើយ ទើបបានសម្រេចការនៅ ។

ព្រះសាស្តាកាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុក (នឿយណាយក្នុងព្រហ្មចារ្យ) ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា ឧទេតយញ្ចក្ខុមា ឯករាជា (ព្រះអាទិត្យនេះជាកែវភ្នែករបស់លោកជាម្ចាស់នៃពន្លឺយ៉ាងឯក កំពុងរះឡើងមក) ដូច្នេះ ។

ភិក្ខុទាំងឡាយនាំភិក្ខុនោះទៅគាល់ព្រះសាស្តា កាលព្រះអង្គត្រាស់សួរថា "អ្នកអផ្សុកពិតឬ?" ភិក្ខុនោះក្រាបទូលថា "ពិតមែន ព្រះអង្គ" កាលត្រាស់សួរថា "អ្នកឃើញអ្វីទើបអផ្សុក?" ភិក្ខុនោះក្រាបទូលថា "ឃើញមាតុគ្រាមម្នាក់ដែលប្រដាប់តាក់តែងកាយ" ។ ព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា "ម្នាលភិក្ខុ ដែលឈ្មោះថាមាតុគ្រាម ហេតុអ្វីមិនចាក់ដោតចិត្តរបស់អ្នកទៅកើត សូម្បីបណ្ឌិតអំពីកាលមុន ពេលបានឮសំឡេងមាតុគ្រាម កិលេសដែលស្ងប់មកអស់ ៧០០ ឆ្នាំ បានឱកាសក៏កម្រើកភ្លាមមួយរំពេច សត្វទាំងឡាយសូម្បីបរិសុទ្ធ នៅសៅហ្មងបាន សូម្បីសត្វដែលបរិបូណ៌ទៅដោយយសសក្តិ ក៏ដល់នូវសេចក្តីវិនាសបាន ទង់ពោលទៅថ្វីដល់សត្វអ្នកមិនបរិសុទ្ធ" ហើយទ្រង់នាំយករឿងអតីតមក

ត្រាស់តំណាល ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វបានបដិសន្ធិក្នុងកំណើតជាសត្វក្ងោក ក្នុងវេលានៅជាពង មានសំបកពងស្រដៀងពណ៌នៃផ្កាកណ៌ិការក្រពុំ លុះទម្លាយសំបកពងចេញមកហើយ មានពណ៌ដូចមាស គួរមើល គួរជ្រះថ្លា មានធ្នូតពណ៌ក្រហមត្រង់ចន្លោះនៃស្លាប ។ ក្ងោកនោះ រក្សាជីវិតរបស់ខ្លួនអាស្រ័យនៅត្រង់ភ្នំទណ្ឌកហិរញ្ញមួយកន្លែង ជិតជួរភ្នំទី ៤ ហួសអំពីជួរភ្នំទី ៣ ទៅ ។ ពេលភ្លឺ ក្ងោកមាសទំនៅលើកំពូលភ្នំ សម្លឹងមើលព្រះអាទិត្យកំពុងរះ កាលទ័ងចងមន្តដ៏ប្រសើរដើម្បីរក្សាការពារខ្លួនទៅត្រង់ភូមិភាគដែលស្វែងរកអាហារ ទើបពោលពាក្យជាដើមថា ឧទេតយំ ដូច្នេះ សេចក្ដីថា

ឧទេតយញ្ចក្ខុមា ឯករាជា

ហរិស្សវណ្ណោ បឋវិប្បភាសោ

តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ

តយជ្ជ គុត្តា វិហរេមុ ទិវសំ

ព្រះអាទិត្យជាកែវភ្នែករបស់លោក ជាម្ចាស់នៃពន្លឺយ៉ាងឯក កំពុងរះឡើងមកផ្សាយនូវពន្លឺពណ៌មាសភ្លឺស្វាងទូទៅប្រឹថពី ព្រោះហេតុនោះ ខ្ញុំសូមនមស្ការព្រះអាទិត្យនោះ ដែលផ្សាយពន្លឺពណ៌មាសភ្លឺស្វាងទូទៅប្រឹថពី ខ្ញុំដែលលោកជួយគ្រប់គ្រងហើយក្នុងថ្ងៃនេះ គប្បីនៅជាសុខរហូតអស់ថ្ងៃ ។

ក្នុងបទទាំងនោះ បទថា ឧទេតិ (កំពុងរះឡើង) បានដល់ ព្រះអាទិត្យរះឡើងចាកលោកធាតុ នាទិសបូព៌ា ។ បទថា ចក្ខុមា (ជាភ្នែក) បានដល់ មានភ្នែក ព្រោះជាភ្នែកឲ្យដល់ប្រជាជន ព្រោះកម្ចាត់សេចក្តីងងឹត ធ្វើឲ្យសត្វដែលនៅក្នុងចក្រវាឡទាំងអស់បាននូវភ្នែក ។ បទថា ឯករាជា (ជាម្ចាស់នៃពន្លឺយ៉ាងឯក) សេចក្តីថា ឈ្មោះថា ជាឯករាជ ព្រោះប្រសើរបំផុត ក្នុងរវាងវត្ថុដែលធ្វើឲ្យលោកភ្លឺស្វាងក្នុងចក្រវាឡទាំងមូល ។ បទថា ហរិស្សវណ្ណោ (ផ្សាយនូវពន្លឺពណ៌មាស)

គឺ មានពណ៌ដូចមាស អធិប្បាយថា មានពណ៌ស្អាតក្រៃលែង ។ បទថា បឋវិប្បភាសោ (ផ្សាយទូទៅលើប្រថពី) គឺ មានពន្លឺលើផែន ។ បទថា តំ តំ នមស្សាមិ (សូមនមស្ការព្រះអាទិត្យនោះ) គឺ ខ្ញុំសូមនមស្ការ គឺ សំពះលោកដ៏ចម្រើននោះ ។ បទថា តយជ្ជ គុត្តា វិហរេមុ ទិវសំ (ខ្ញុំដែលលោកជួយគ្រប់គ្រងហើយក្នុងថ្ងៃនេះ គប្បីនៅជាសុខអស់ថ្ងៃនេះ) សេចក្តីថា សូមឲ្យលោករក្សាគ្រប់គ្រងក្នុងថ្ងៃនេះ ខ្ញុំគប្បីនៅជាសុខរហូតអស់ថ្ងៃនេះ ដោយការនៅក្នុងឥរិយាបថទាំង ៤ ។

ព្រះពោធិសត្វលុះនមស្ការព្រះអាទិត្យដោយគាថានេះ យ៉ាងនេះហើយ ទើបនមស្ការព្រះពុទ្ធដែលស្តេចបរិនិព្វានទៅហើយក្នុងអតីត និងគុណរបស់ព្រះពុទ្ធ ដោយគាថាទី ២ ថា

យេ ព្រាហ្មណា វេទគូ[១] សព្វធម្មេ
តេ មេ នមោ តេ ច មំ បាលយន្តុ
នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា
នមោ វិមុត្តានំ នមោ វិមុត្តិយា

ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា ។

ព្រាហ្មណ៍ពួកណាជាអ្នកដល់នូវវេទក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងនោះ ចូរទទួលការនមស្ការរបស់ខ្ញុំ ទំាំងសូមចូរគ្រប់គ្រងខ្ញុំផង ខ្ញុំសូមនមស្ការចំពោះព្រះពុទ្ធទាំងឡាយ សូមនមស្ការចំពោះព្រះពោធិញ្ញាណ សូមនមស្ការចំពោះលោកអ្នករួចផុតហើយ សូមនមស្ការចំពោះវិមុត្តិធម៌របស់លោកអ្នករួចផុតហើយ ក្ងោកនោះចម្រើនព្រះបរិត្តនេះហើយ ទើបត្រាច់ទៅស្វែងរកអាហារ ។

ក្នុងបទទាំងនោះ បទថា យេ ព្រាហ្មណា (ព្រាហ្មណ៍ពួកណា) បានដល់ ព្រាហ្មណ៍ដែលបរិសុទ្ធ បន្សាត់បាបហើយពួកណា ។ បទថា វេទគូ (ជាអ្នកដល់នូវវេទ) សេចក្តីថា ឈ្មោះថា អ្នកដល់នូវវេទ ព្រោះដល់ត្រើយនៃវេទ ។ម្យ៉ាងទៀត ឈ្មោះថា អ្នកដល់នូវវេទដោយព្រះវេទខ្លះ ។ តែក្នុងទីនេះមានអធិប្បាយថា លោកអ្នកធ្វើសង្ខតធម៌ និងអសង្ខតធម៌ទាំងពួងដែលខ្លួនដឹងហើយ ប្រាកដហើយ ទម្លាយនូវកំពូលមារទាំង ៣ ញុំាំងម៉ឺនលោកធាតុឲ្យញាប់ញ័រ សម្រេចសម្មាសម្ពោធិ-

ញ្ញាណត្រង់គល់ពោធិព្រឹក្ស កន្លងត្រ័យនៃសង្គ្រាមបានហើយ ។ បទថា តេ មេ នមោ (ចូរទទួលការនមស្ការរបស់ខ្ញុំ) គឺ សូមព្រាហ្មណ៍ទាំងនោះ ចូរទទួលការនមស្ការនេះរបស់ខ្ញុំ ។ បទថា តេ ច មំ បាលយន្តុ (សូមលោកទាំងនោះចូររក្សាខ្ញុំផង) សេចក្តីថា ម្យ៉ាងទៀត សូមលោកដ៏ចម្រើនទាំងនោះដែលខ្ញុំនមស្ការហើយយ៉ាងនេះ ចូររក្សា គឺ ថែរក្សាគ្រប់គ្រងខ្ញុំ ។ បទថា នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា នមោ វិមុត្តានំ នមោ វិមុត្តិយា (ខ្ញុំសូមនមស្ការចំពោះព្រះពុទ្ធទាំងឡាយ សូមនមស្ការចំពោះព្រះពោធិញ្ញាណ សូមនមស្ការចំពោះលោកអ្នករួចផុតហើយ សូមនម-ស្ការចំពោះវិមុត្តិធម៌របស់លោកអ្នករួចផុតហើយ) ន័យថា ការនមស្ការរបស់ខ្ញុំនេះ ចូរមានចំពោះព្រះពុទ្ធទាំងឡាយ ដែលស្តេចទ្រង់បរិនិព្វានកន្លងទៅហើយ គឺ ចូរមានចំពោះព្រះញាណដែលត្រាស់ដឹង បានដល់ញាណក្នុងមគ្គ ៤ ផល ៤ របស់ព្រះពុទ្ធទាំងនោះ ។ ម្យ៉ាងទៀត សូមចូរមានចំពោះព្រះអង្គទ្រង់រួចផុតហើយ ដោយការរួចផុត គឺ ព្រះអរហត្តផលរបស់ព្រះអង្គ ទ័ងការរួចផុត ៥ យ៉ាងរបស់ព្រះអង្គ គឺ តទង្គវិមុត្តិ (រួច

ផុតដោយខណៈ) ១, វិក្ខម្ភនវិមុត្តិ (រួចផុតដោយការគ្របសង្កត់ទុក) ១, សមុច្ឆេទវិមុត្តិ (រួចផុតដោយដាច់ស្រឡះ) ១, បដិប្បស្សទ្ធិវិមុត្តិ (រួចផុតដោយសេចក្តីស្ងប់) ១, និស្សរណវិមុត្តិ (រួចផុតដោយការចេញទៅ) ១ ។ សូមការនមស្ការរបស់ខ្ញុំនេះ ចូរមានសូម្បីដល់ការរួចផុត ៥ យ៉ាងរបស់ព្រះអង្គទាំងនោះ ។

បទថា ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា (ក្ងោកនោះចម្រើនព្រះបរិត្តនេះហើយ ទើបត្រាច់ទៅស្វែងរកអាហារ) នេះ ព្រះសាស្តាត្រាស់កាលបានសម្រេចអភិសម្ពោធិញ្ញាណហើយ ។ ពាក្យនោះមានអធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ក្ងោកនោះលុះចម្រើនបរិត្តនេះ គឺ ការការពារនេះហើយ ទើបត្រាច់ទៅស្វែងរកអាហារនានា មានផ្កាឈើផ្លែឈើជាដើមក្នុងទីរកអាហាររបស់ខ្លួន ។

ក្ងោកកាលត្រាច់ទៅអស់មួយថ្ងៃយ៉ាងនេះហើយ ពេលល្ងាចក៏ទំលើកំពូលភ្នំសម្លឹងមើលព្រះអាទិត្យដែលកំពុងលិច រឭកដល់ព្រះពុទ្ធគុណកាលទីងចងមន្តដ៏ប្រសើរទៀត ដើម្បីរក្សាដល់ទីនៅ ទើបពោលគាថាមាន

ជាដើមថា អបេតយំ ដូច្នេះ សេចក្តីថា

អបេតយញ្ចក្ខុមា ឯករាជា

ហរិស្សវណ្ណោ បឋវិប្បភាសោ

តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ

តយជ្ជ គុត្តា វិហរេមុ រត្តិំ

យេ ព្រាហ្មណា វេទគុ សព្វធម្មេ

តេ មេ នមោ តេ ច មំ បាលយន្តុ

នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា

នមោ វិមុត្តានំ នមោ វិមុត្តិយា

ឥមំ សោ បរិត្តំ កត្វា មោរោ វាសមកប្បយីតិ ។

ដូនព្រះអាទិត្យនេះ ជាភ្នែករបស់លោក ជាម្ចាស់នៃពន្លឺយ៉ាងឯក មានពណ៌មាសផ្សាយទៅទូទាំងប្រថពី ហើយអស្តង្គតទៅ ព្រោះហេតុនោះ ខ្ញុំសូមនមស្ការព្រះអាទិត្យនោះ ដែលមានពណ៌មាសផ្សាយទូទាំងប្រថពី ខ្ញុំដែលលោករក្សាហើយក្នុងថ្ងៃនេះ គប្បីនៅ

ជាសុខអស់យប់នេះ ។

ព្រាហ្មណ៍ពួកណា ជាអ្នកដល់នូវវេទក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ពួកនោះ ចូរទទួលនូវការនមស្ការរបស់ខ្ញុំ និងចូររក្សាខ្ញុំផង ខ្ញុំសូមនមស្ការចំពោះព្រះពុទ្ធទាំងឡាយ សូមនមស្ការចំពោះព្រះពោធិ-ញ្ញាណ សូមនមស្ការចំពោះលោកអ្នករួចផុតហើយ សូមនមស្ការចំពោះវិមុត្តិធម៌របស់លោកអ្នករួចផុតហើយ ក្ងោកនោះចម្រើនព្រះបរិត្តនេះហើយ ទើបដេក ។

ក្នុងបទទាំងនោះ បទថា អបេតិ (អស្តង្គតទៅ) បានដល់ រលត់ទៅ គឺ លិចទៅ ។ សូម្បីបទថា ឥមំ សោ បរិត្តំ កត្វា មោរោ វាស-មកប្បយិ (ក្ងោកនោះចម្រើនព្រះបរិត្តនេះហើយ ទើបដេក) នេះ ព្រះសាស្ដាក៏ត្រាស់ព្រះគាថានេះ កាលទ្រង់លុះអភិសម្ពោធិញ្ញាណហើយ ។ ពាក្យនោះមានអធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ក្ងោកនោះគ្រាបចម្រើនព្រះបរិត្ត គឺ ការការពារនេះហើយ ទើបដេកត្រង់ទីនៅនោះ ។ ដោយអានុភាពនៃព្រះបរិត្តនេះ ក្ងោកមិនមានសេចក្ដីភ័យខ្លាច សេចក្ដីតក់ស្លុត

អស់យប់មួយថ្ងៃមួយ ។

លំដាប់នោះ ព្រាននេសាទម្នាក់ នៅមិនឆ្ងាយអំពីក្រុងពារាណសី ត្រាច់ទៅក្នុងហិមពាន្តប្រទេស ឃើញក្ងោកពោធិសត្វទំនៅលើកំពូលភ្នំ ទណ្ឌកហិរញ្ញ ទើបត្រឡប់មកប្រាប់កូន ។ ក្រោយមកថ្ងៃមួយ ព្រះនាងខេមាព្រះទេវីរបស់ព្រះបាទក្រុងពារាណសី ទ្រង់សុបិនឃើញក្ងោកពណ៌មាសសម្ដែងធម៌ ខណៈភ្ញាក់ពីព្រះបន្ទំ បានក្រាបទូលសុបិននោះចំពោះព្រះរាជាថា "ព្រះសម្មតិទេព ខ្ញុំព្រះអង្គបំណងទ័ងស្ដាប់ធម៌របស់ក្ងោកពណ៌មាស ព្រះអង្គ" ។ ព្រះរាជាទើបមានព្រះតម្រាស់សួរពួកអាមាត្យ ពួកអាមាត្យក្រាបទូលថា "ពួកព្រាហ្មណ៍គង់ទ័ងជ្រាបព្រះអង្គ" ។ ព្រាហ្មណ៍ទាំងឡាយស្ដាប់រាជបុច្ឆាហើយ ទើបនាំគ្នាក្រាបទូលថា "ព្រះសម្មតិទេព ក្ងោកពណ៌មាសមានពិត" ។ ព្រះរាជាត្រាស់សួរថា "មាននៅក្នុងទីណា?" ទើបក្រាបទូលថា "ពួកព្រានទ័ងដឹង ព្រះអង្គ" ។ ព្រះរាជាត្រាស់ឲ្យប្រជុំពួកព្រានហើយត្រាស់សួរ ។ គ្រានោះ បុត្តព្រានម្នាក់នោះក៏ក្រាបទូលថា "បពិត្រមហារាជ ក្ងោកពណ៌មាសមានពិត អាស្រ័យនៅត្រង់ទណ្ឌ-

កបពិត ព្រះអង្គ" ។ ព្រះរាជាត្រាស់បន្ទាប់ថា "បើដូច្នោះ អ្នកចូរទៅ
ចាប់ក្ងោកនោះមកកុំឲ្យស្លាប់" ។ ព្រានទើបយកអន្ទាក់ទៅដាក់ត្រង់កន្លែង
ដែលក្ងោករកអាហារ ។ សូម្បីស្ថានទីដែលក្ងោកជាន់ អន្ទាក់ក៏ជ្លោះមិន
បាន ។ ព្រានមិនអាចនឹងចាប់ក្ងោកបាន ស្វែងរកចាប់រហូតអស់ ៧ ឆ្នាំ
ក៏បានស្លាប់នៅក្នុងទីនោះឯង ។ សូម្បីព្រះនាងខេមារាជទេវី កាលមិន
បានសមបំណងក៏អស់ព្រះជន្ម ។ ព្រះរាជាទ្រង់ក្រោធថា ព្រះទេវីបាន
អស់ព្រះជន្មព្រោះអាស្រ័យក្ងោក ដូច្នេះ ទើបឲ្យចារឹកអក្សរទុកក្នុងផែន
មាសថា ក្នុងហិមពាន្តប្បទេស មានភ្នំមួយឈ្មោះទណ្ឌកបពិត ក្ងោក
ពណ៌មាសមួយអាស្រ័យនៅទីនោះ អ្នកណាបានស៊ីសាច់ក្ងោកនោះ អ្នក
នោះមិនចាស់មិនស្លាប់ និងមានអាយុវែង ដូច្នេះ ហើយរក្សាផែនមាស
ទុកក្នុងហិបមាស ។ លុះព្រះរាជាទ្រង់សោយទិវង្គតទៅ ព្រះរាជាអង្គ
ដទៃគ្រប់គ្រងរាជសម្បត្តិ ទ្រង់អានសេចក្ដីក្នុងសុវណ្ណបដ: ក៏មានព្រះ
បំណងនឹងមិនចង់ចាស់មិនចង់ស្លាប់ ទើបទ្រង់បញ្ជូនព្រានដទៃទៅ ឲ្យ
ស្វែងរក ។ សូម្បីព្រាននោះទៅដល់ទីនោះហើយ ក៏មិនអាចនឹងចាប់ព្រះ

ពោធិសត្វបាន បានស្លាប់ក្នុងទីនោះឯង ។ ដោយទំនងនេះ ព្រះរាជាទ្រង់សោយទិវង្គតអស់ ៦ ដូវវង្ស (៦ ជំនាន់) ។ គ្រាដល់អន្តទី ៧ គ្រងរាជសម្បត្តិ ទើបទ្រង់បញ្ជូនព្រានម្នាក់ទៅ ។ ព្រាននោះទៅហើយក៏ដ៏ងដល់ការៈដែលអន្ទាក់មិនថ្ងោះ សូម្បីក្នុងទីដែលក្ងោកពោធិសត្វជាន់ព្រោះក្ងោកពោធិសត្វចម្រើនព្រះបរិត្តការពារខ្លួនមុនហើយ ទើបហើរទៅរកអាហារ ទើបទៅកាន់បច្ចន្តជនបទ ចាប់ក្ងោកញីបានមួយក្បាល ហ្វឹកហាត់ឲ្យចេះរាំដោយសំឡេងទះដៃ និងឲ្យចេះរងាវដោយផ្ទាត់ម្រាមដៃ ។ លុះហ្វឹកហាត់ក្ងោកញីរហូតជំនាញល្អហើយ ទើបនាំក្ងោកញីទៅ កាលក្ងោកមាសនៅមិនទាន់ចម្រើនព្រះបរិត្ត បានដាក់អន្ទាក់ទុកក្នុងវេលាព្រឹកធ្វើសញ្ញាឲ្យក្ងោកញីរងាវ ។ ក្ងោកមាសបានឮសំឡេងរបស់មាតុគ្រាមដែលជាសត្រូវហើយ ក៏រសាប់រសល់ដោយកិលេស មិនអាចចម្រើនព្រះបរិត្តបាន ទើបហើរទៅជាប់អន្ទាក់ ។ ព្រានទើបចាប់ក្ងោកមាសទៅថ្វាយព្រះបាទក្រុងពារាណសី ។

ព្រះរាជាទតព្រះនេត្រឃើញរូបសម្បត្តិរបស់ក្ងោកមាស ទ្រង់ពេញ

ព្រះទ័យ ព្រះរាជទានបន្ទន់ឲ្យទំ ។ ក្មេកមាសពោធិសត្វទំទៅលើបន្ទន់ដែលគេរៀបចំឲ្យ ទើបទូលសួរថា "បពិត្រមហារាជ ព្រោះហេតុអ្វីទើបមានព្រះតម្រាស់ឲ្យចាប់ខ្ញុំ" ។ ព្រះរាជាត្រាស់ថា "ឮថា អ្នកណាបានស៊ីសាច់អ្នក អ្នកនោះនឹងមិនចាស់មិនស្លាប់ ខ្ញុំត្រូវការស៊ីសាច់អ្នក ទើងមិនចាស់មិនស្លាប់ ទើបឲ្យចាប់អ្នកមក" ។ ក្មេកមាសទូលថា "បពិត្រមហារាជ ជនទាំងឡាយស៊ីសាច់ខ្ញុំ ទើងមិនចាស់មិនស្លាប់ ក៏ហើទៅចុះតែខ្ញុំនឹងស្លាប់ឬ" ។ ត្រាស់ថា "អ្នកពិតជាត្រូវស្លាប់" ។ ក្មេកមាសក្រាបទូលថា "បពិត្រមហារាជ បើខ្ញុំត្រូវស្លាប់ អ្នកដែលស៊ីសាច់ខ្ញុំហើយធ្វើយ៉ាងណាទើបមិនស្លាប់" ។ ព្រះរាជាត្រាស់ថា "ខ្លួនអ្នកមានពណ៌ដូចមាស ព្រោះដូច្នោះទើបបានឮថា អ្នកដែលស៊ីសាច់អ្នកហើយ ទើងមិនចាស់មិនស្លាប់" ។ ក្រាបទូលថា "បពិត្រមហារាជ ខ្ញុំមានពណ៌មាសព្រោះមិនមានហេតុក៏មិនមែន កាលមុន ខ្ញុំជាស្ដេចចក្រពត្តិក្នុងនគរនេះឯង ទាំងខ្លួនឯងក៏រក្សាសីល ៥ សូម្បីជនទាំងឡាយទូទៅក្នុងចក្រវាឡក៏ឲ្យរក្សាសីល ខ្ញុំអស់ជីវិតហើយក៏ទៅកើតក្នុងភពតាវត្តិង្ស តាំងនៅក្នុង

កពនោះផងរាបដល់អស់អាយុ ចុតិអំពីនោះហើយ ទើបមកកើតក្នុងកំណើតសត្វក្ងោក ព្រោះផលនៃអកុសលកម្មដទៃឯណានីមួយ តែខ្លួនខ្ញុំមានពណ៌មាសក៏ដោយអានុភាពសីល ៤ ដែលរក្សាក្នុងកាលមុន" ។ ត្រាស់សួរថា "អ្នកពោលថា អ្នកជាស្តេចចក្រពត្តិរក្សាសីល ៤ ខ្លួនមានពណ៌មាសព្រោះផលរបស់សីល ប្រការនេះខ្ញុំនឹងជឿដូចម្តេចបាន មានអ្នកណាជាសាក្សី?" ក្រាបទូលថា "បពិត្រមហារាជ មាន" ។ ព្រះរាជាត្រាស់សួរថា "នរណា?" ក្រាបទូលថា "បពិត្រមហារាជ ក្នុងគ្រាជាស្តេចចក្រពត្តិខ្ញុំអង្គុយលើរថដែលសម្រេចដោយកែវ ៧ ប្រការ ត្រាច់ទៅក្នុងអាកាសរថរបស់ខ្ញុំនោះលិចចុះខាងក្រោមនៃស្រះមង្គលបោក្ខរណី ប្រោសឲ្យលើករថនោះឡើងអំពីស្រះមង្គលបោក្ខរណីចុះ រថនោះនឹងសាក្សីរបស់ខ្ញុំ" ។

ព្រះរាជាត្រាស់ថា "ល្អហើយ" ហើយឲ្យបាចទឹកចេញអំពីស្រះបោក្ខរណីលើករថឡើងបាន ទើបទ្រង់ជឿពាក្យរបស់ព្រះពោធិសត្វ ។ ព្រះពោធិសត្វសម្តែងធម៌ថ្វាយព្រះរាជាថា "បពិត្រមហារាជ ធម៌ដែលបច្ច័យតាក់តែងទាំងអស់ផ្សេងៗក្រៅអំពីអមតមហានិព្វានហើយ ឈ្មោះ

ថាមិនទៀង មានការអស់ទៅ ទិនសូន្យទៅជាធម្មតា ព្រោះមានហើយត្រឡប់ទៅជាមិនមានវិញ" ដូច្នេះហើយ ឲ្យព្រះរាជាតាំងនៅក្នុងសីល ៥ ។ ព្រះរាជាទ្រង់ជ្រះថ្លាបូជាព្រះពោធិសត្វដោយរាជសម្បត្តិ ទ្រង់បានធ្វើសក្ការៈជាច្រើន ។ ក្ងោកមាសថ្វាយរាជសម្បត្តិចំពោះព្រះរាជា ស្នាក់នៅ ២-៣ ថ្ងៃ ទើបថ្វាយឱវាទថា "បពិត្រមហារាជ សូមទ្រង់ចូរតាំងនៅដោយសេចក្ដីមិនប្រមាទចុះ" ហើយហើរកាន់អាកាសទៅកាន់ភ្នំទណ្ឌកហិរញ្ញវិញ ។ ចំណែកព្រះរាជាតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វហើយ ទ្រង់បំពេញបុណ្យមានទានជាដើម ហើយប្រព្រឹត្តទៅតាមកម្ម ។

ព្រះសាស្ដាកាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ប្រជុំជាតក ។ កាលចប់សច្ចធម៌ ភិក្ខុដែលអផ្សុកក៏បានតាំងនៅក្នុងព្រះអរហត្ត ។ ព្រះរាជាក្នុងគ្រានោះ បានមកជាព្រះអានន្ទ ចំណែកក្ងោកមាសបានមកជា តថាគត នេះឯង ។

ចប់អដ្ឋកថា មោរជាតកទី ៥